00630835

 លេខ/No: D427/4/13

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / 12 / 2010
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ១០៩)

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: បារាំង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គបុរេជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ចម្លើយតបនៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ជំនួយការ**

លោកស្រី សេង សុជាតា

លោក M. Frédéric HIVON

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

<u>ផ្ញើជូន៖</u>

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និង**

**ដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានតំណាង**

# សូមគោរពអង្គបុរេជំនុំជម្រះ

## I- សេចក្តីផ្តើម

១. ដោយអនុលោមទៅតាមមាត្រា ៨.៤ នៃ "សេចក្តីណែនាំពាក់ព័ន្ធនឹងការដាក់ឯកសារ" និងសេចក្តីណែនាំនៃអង្គបុរេជំនុំជម្រះ[1] លោកខៀវ សំផន សូមឆ្លើយតប ទៅនឹងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ("ចម្លើយ")[2] ព្រមទាំងទៅនឹងកថាខណ្ឌទាំង១៧ដំបូង នៃចម្លើយរួមរបស់សហព្រះរាជអាជ្ញា ដែលឆ្លើយទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ[3]។

២. ទៅតាមទម្លាប់នៃប្រព័ន្ធច្បាប់ *civil law* ដែលផ្តល់អាទិភាពដល់ចៅក្រម ក៏ដូចជាក្នុងច្បាប់កម្ពុជាដែលមានប្រភពពីប្រព័ន្ធច្បាប់នោះ នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលស៊ើបអង្កេត *"ដែលត្រូវធ្វើជាដាច់ខាត ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក "*[4] និងដំណាក់កាលកាត់សេចក្តីតាមន័យចង្អៀត ដែលនឹងប្រព្រឹត្តឡើង ប្រសិនបើត្រូវធ្វើ ទៅតាមពេលវេលាដែលកំណត់ឡើងដោយចៅក្រមស៊ើបអង្កេត។ ដូច្នេះ គឺចៅក្រមស៊ើបអង្កេតនោះហើយដែលជាអ្នក *"រៀបចំកន្លែងពិភាក្សា ជាអ្នកកំណត់ពេលវេលា ជាអ្នកគូសវង្វង់ព្រំដែនកំណត់"* [5]។ សហចៅក្រមស៊ើបអង្កេតត្រូវមាន <u>**កាតព្វកិច្ចកិច្ច**</u>ផ្តល់ភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដើម្បីស្វែងរកការពិត[6]។ នោះជាលក្ខខណ្ឌចាំបាច់មិនអាចអត់បាន ដើម្បីឱ្យមានជម្រះក្តីមួយនៅចំពោះមុខ អ.វ.ត.ក។

---

[1] "សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះនៅក្នុងក្រុមមេធាវីការពារក្តីរបស់លោក ខៀវ សំផន" អ៊ីម៉ែលចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០ សំណុំរឿងលេខ 002/19-09-2007- អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ 104)

[2] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D427/4/7*

[3] ចម្លើយរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ លោកនួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារតុលាការលេខ *D427/4/12*

[4] វិធាន៥៥(១) នៃវិធានផ្ទៃក្នុង

[5] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D427/4/3* កថាខណ្ឌ ១៥

[6] វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង

00630837



ដំណាក់កាលស៊ើបអង្កេតនេះ ជាការធានាឲ្យបាននូវសិទ្ធិក្នុងការទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌។ ភាពត្រឹមត្រូវនៃការកាត់សេចក្ដីឲ្យបានស៊ីជម្រៅ អាស្រ័យទៅនឹងការតទល់ប្រកបដោយសមភាពនៃដំណាក់កាលដំបូងនេះ។ ដីកាដំណោះស្រាយ ដែលជាពេលចុងបញ្ចប់នៃការស៊ើបអង្កេត[7] និងគ្រឹះនៃកិច្ចពិភាក្សាចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[8] ត្រូវតែគិតដល់ចំណុចចាំបាច់ទាំងអស់នោះ។

៣. វិធាន ២ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក (*"វិធានផ្ទៃក្នុង"*) បានចែងពីនីតិវិធីអនុវត្ត ក្នុងករណីមានការខ្វះចន្លោះនៅក្នុងវិធានផ្ទៃក្នុងនេះ។ នៅទីបញ្ចប់នៃសកម្មភាពស្ថាបនា អ.វ.ត.ក ដោយគិតដល់<u>លក្ខណៈកូនកាត់</u>របស់អង្គជំនុំជម្រះវិសាមញ្ញនេះ "*<u>នីតិវិធីត្រូវបានគ្រប់គ្រងដោយច្បាប់កម្ពុជា</u>*"[9]។ ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ[10] គេអាចស្វែងរកការណែនាំ ក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ ទាំងនេះដូចគ្នាទៅនឹងការទទួលស្គាល់របស់សហព្រះរាជអាជ្ញាដូច្នោះដែរ នៅក្នុងចម្លើយរបស់ខ្លួនដែលសរសេរថា ៖ "*វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក បានបង្កើតឡើងនូវប្រព័ន្ធនីតិវិធីមួយសម្រាប់តុលាការពិសេសនេះ ដែលធ្វើឡើងទៅតាមកាលៈទេសៈពិសេសរបស់វា*" ហើយវិធាននេះមិនត្រូវមានករណីលើកលែងឡើយ (កថាខណ្ឌ ១៨)។

៤. តុលាការនេះ ដែលបង្កើតឡើងដោយច្បាប់ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ បានអនុម័តលើកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ បានបង្កើតជាប្រព័ន្ធតុលាការកូនកាត់ ដែលភ្ជាប់ទៅនឹងប្រព័ន្ធច្បាប់ជាតិ ដែលមានភាពខុសប្លែកយ៉ាងច្រើនពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត ជាពិសេសខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា ឬក៏ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ជម្រើសដោយចេតនានៃក្រុមអ្នកបង្កើតអង្គជំនុំជម្រះនេះ ត្រូវតែគោរពឲ្យបានម៉ឺងម៉ាត់ ហើយក៏ត្រូវគោរព

---

[7] វិធាន ៦៧(១) និង ៧៦(៧) នៃវិធានផ្ទៃក្នុង

[8] វិធាន ៧៩(១) និង ៩៨(២) នៃវិធានផ្ទៃក្នុង

[9] មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា

[10] មាត្រា៣៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក

ស្មារតីនៃអ្នកតាក់តែងវិធានផ្ទៃក្នុង ដែលមានបំណងគោរពច្បាប់កម្ពុជាសម្រាប់អនុវត្តក្នុងករណីពិសេស។

៥. "ចម្លើយ"បានបង្ហាញថា សហព្រះរាជអាជ្ញាមិនចេះប្រព័ន្ធច្បាប់កម្ពុជា ដែលជាប្រព័ន្ធច្បាប់ civil law និងគោលបំណងនៃការបិទការស៊ើបអង្កេតឡើយ។ ភាពខុសឆ្គងដ៏ច្បាស់ក្រឡែតរបស់សហព្រះរាជអាជ្ញា លើការវិភាគវាយតម្លៃលើលក្ខណៈនៃបណ្តឹងឧទ្ធរណ៍ ការយោងតែទៅលើច្បាប់នៃតុលាការអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីដែលយកតាមប្រព័ន្ធច្បាប់ common law មកអនុវត្ត ឬការអនុវត្តខុសឆ្គងទៅលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះសុទ្ធតែជាបញ្ហាដ៏ធ្ងន់ធ្ងរ។

៦. ដូច្នេះ លោក ខៀវ សំផន សូមលើកឡើងវិញនូវអំណះអំណាងទាំងឡាយដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍")[11] ហើយសូមឲ្យអង្គបុរេជំនុំជម្រះ មេត្តា៖

- ច្រានចោល រាល់អំណះអំណាងរបស់សហព្រះរាជអាជ្ញា
- ប្រកាសទទួលស្គាល់ថា "បណ្តឹងឧទ្ធរណ៍"អាចទទួលយកបាន និងមានមូលដ្ឋានត្រឹមត្រូវ។

៧. ដោយហេតុនេះ ៖

- ត្រូវរំលាយចោលដីកាដំណោះស្រាយ[12]
- បង្គាប់ឲ្យដោះលែងរូបគាត់ ឲ្យមានសេរីភាពឡើងវិញ
- បង្គាប់ឲ្យបន្តធ្វើការស៊ើបអង្កេតតទៅទៀត។

៨. ទោះក្នុងករណីណាក៏ដោយ ៖

- វិនិច្ឆ័យថា មិនអាចបញ្ជូនសំណុំរឿងលោក ខៀវ សំផន ទៅជម្រះ ក្នុងសភាពមិនគ្រប់ជ្រុងជ្រោយបែបនេះបានឡើយ។

---

[11] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D427/4/3*

[12] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D427*

00630839



## II- អំណះអំណាងក្នុងចម្លើយតប

### ១. កំហុសជាក់ស្តែងក្នុងការវាយតម្លៃរបស់សហព្រះរាជអាជ្ញា

៩. នៅក្នុង "ចម្លើយ" សហព្រះរាជអាជ្ញាបានទទួលគាំទ្រថា"បណ្តឹងឧទ្ធរណ៍"បានត្រឹមតែលើកឡើងពី "វិការៈក្នុងទម្រង់នៃដីកាដំណោះស្រាយ និងវិការៈនៃនីតិវិធីក្នុងដំណើរការការនៃការស៊ើបសួរ" (កថាខណ្ឌ៣ និង៤) ចំណែកឯ "បណ្តឹងឧទ្ធរណ៍" បានសង្កេតឃើញថា ដីកាដំណោះស្រាយបានបញ្ចប់ការស៊ើបសួរមិនពេញលេញមួយនៅមុនពេលកំណត់ ឯការស៊ើបសួរទៀតសោតសុទ្ធតែធ្វើឡើងដើម្បីដាក់បន្ទុកប៉ុណ្ណោះ ដែលជាការរំលោភដល់សិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌របស់លោក ខៀវ សំផន។ ដោយកម្រិតត្រឹមតែបដិសេធមិនទទួលអំណះអំណាងដែលលើកឡើងដោយក្រុមមេធាវីការពារក្តី សហព្រះរាជអាជ្ញាមានចេតនាជ្រុលហួសហេតុក្នុងការកំណត់ព្រំដែននៃកិច្ចពិភាក្សា ដើម្បីគេចវេសមិនពិភាក្សាឱ្យស៊ីជម្រៅ ដែលជាការមាក់ងាយដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ។

១០. Hannah Arendt អ្នកសង្កេតការណ៍ដ៏ពូកែ នៅក្នុងរឿងក្តីរបស់លោក Eichmann បង្ហាញប្រាប់ពីបញ្ហាដ៏ធំនៃការបោកបញ្ឆោតបែបនេះ ដោយមានប្រសាសន៍ថា ៖ "*ការកាត់ក្តីតែងតែបង្កើតឱ្យមានជាការពិភាក្សានយោបាយ ដែលក្លាយទៅជាឧបករណ៍សម្រាប់កែបន្លំដោយភាគីដើមចោទ*" ដើម្បីផ្តន្ទាទោសជនជាប់ចោទឱ្យបានឆាប់រហ័ស ដោយសារតែចង់បាន **<u>ប្រសិទ្ធភាពផ្នែកនយោបាយ</u>** និងដើម្បីរាំងស្ទះដល់ការផ្តល់អំណះអំណាងគតិយុត្តិ ដែលជាលទ្ធផលនៃការពិភាក្សាចំពោះមុខប្រកបដោយគុណភាព។ អ្នកស្រីក៏បានបញ្ជាក់បន្ថែមក្នុងសំណេរថា ៖ "*ដោយសារតែខាងដើមចោទអារម្មណ៍ជាពិសេសតែទៅលើការឈឺចាប់របស់ប្រជាជនជ្វីហ្វ និងដល់ទំហំនៃអំពើប្រល័យពូជសាសន៍ ដែលប្រជាជនជ្វីហ្វនោះបានទទួលរងវាជាការសមហេតុសមផលដែលត្រូវចាប់ផ្តើមពីចំណុចនោះ ហើយបន្ទាប់មកទៀត ពិនិត្យឃើញថា តើ<u>ការទទួលខុសត្រូវពិសេសលើរឿងដ៏អាក្រក់អាក្រីនោះអាចត្រូវដាក់បន្ទុកទៅលើជនជាប់ចោទ</u>ខ្លាំងក្លាដល់កម្រិតណានោះ* "។

១១. ការអះអាងរបស់សហព្រះរាជអាជ្ញា ដែលថា "*ដើមបណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យអង្គបុរេជំនុំជម្រះមានការមោឃភាពដីកាដំណោះស្រាយ* " (កថាខណ្ឌ១ និង១៣) ក៏មានការខុសឆ្គងដែរ។ ដូចការរំឭកនៃបណ្តឹងឧទ្ធរណ៍ លោក ខៀវ សំផន សុំឱ្យ<u>លុបចោល</u>ដីកាដំណោះស្រាយ គឺមានន័យថា "*រំលាយចោលដីកាដំណោះស្រាយ ដែលនាំឱ្យមានការបើកឡើងវិញ*

*នូវដំណាក់កាលនៃសំណុំរឿងដូចមុន*"[13]។ ដូច្នេះ លោកសុំឱ្យបន្តការស៊ើបអង្កេត ពីព្រោះថា ការបញ្ជូនសំណុំរឿងរបស់លោកទៅជម្រះ ក្នុងសភាពមិនគ្រប់ជ្រុងជ្រោយបែបនេះ ពិតជាមិនអាចធ្វើអាចធ្វើទៅបានឡើយ។

១២. ដូចគ្នានេះដែរ ផ្ទុយពីការចោទប្រកាន់នៃដើមចោទ នេះពុំមែនជាបណ្តឹងសុំមោឃភាព ដោយយោងតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងនោះសោះឡើយ (កថាខណ្ឌ១២ និង១៣)។ លើសពីនោះទៀត លោកខៀវ សំផន បានដាក់បណ្តឹងពីរខុសពីគ្នា គឺបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបណ្តឹងឧប្បត្តិហេតុដោយមូលហេតុរំលោភនីតិវិធី[14] ដែលជាសេចក្តីបន្ថែម និងបន្ទាប់បន្សំ ហើយពុំមាន "*លាយឡំជាមួយនឹងការស្នើសុំព្យួរនីតិវិធី និងការស្នើសុំបណ្តឹងឧទ្ធរណ៍ដើម្បីសុំលុបចោលនីតិវិធីនោះឡើយ*" (កថាខណ្ឌ១៥)។ គឺសហព្រះរាជអាជ្ញាជាអ្នកច្រឡំដោយខ្លួនឯងទាំងស្រុង លើបណ្តឹង អត្ថន័យនៃបណ្តឹងទាំងនោះ និងជាពិសេស ស្មារតីនៃការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងដោយមានការជជែកពិភាក្សាគ្នា ដែលជាខ្លឹមសារគោលនៃប្រព័ន្ធច្បាប់ civil law ។

## ២. បណ្តឹងឧទ្ធរណ៍មានលក្ខណៈអាចទទួលយកបាន

១៣. នៅក្នុងវិធាន ៦៧ (៥) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយអាចបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន៧៤ ដែលបង្ហាញនូវបញ្ជីលម្អិត <u>តែមិនមានកម្រិត</u>នៃសេចក្តីសម្រេច ដែលអាចបើកផ្លូវប្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ។ ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយខុសគ្នាលើវិធាននេះ អាចនាំឱ្យផ្ទុយទៅនឹងគោលការណ៍សមភាពនៃការការពារក្តី។ អនុលោមតាមវិធាន ៧៤ (៣) (ក) "*ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក*"។

១៤. ដូចសេចក្តីគូសបញ្ជាក់របស់លោក ខៀវ សំផន នៅក្នុងបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយ គឺជា "*សេចក្តីសម្រេចដែលទទួលស្គាល់យុត្តាធិការរបស់ អ.វ.ត.ក*" ទៅតាមអត្ថន័យនៃ

---

[13] CORNU (G.), *Vocabulaire juridique*, Presses universitaires de France, ពាក្យ "Révocation", ទំព័រ៨០០ (ក្នុងឧបសម្ព័ន្ធ)

[14]បណ្តឹងឧប្បត្តិហេតុដើម្បីបញ្ឈប់ភ្លាមៗ និងជាស្ថាពរនូវនីតិវិធីប្រឆាំងនឹងលោក ខៀវ សំផន ដោយមូលហេតុរំលោភនីតិវិធី ថ្ងៃទី១៨ តុលា ២០១០ សំណុំរឿងលេខ 002/21-10-2010-អវតក/អបជ ១៥ ឯកសារតុលាការ ១

00630841



វិធាន ៧៤ (៣) (ក)[15] ដែលទទួលជម្រះដោយអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលដីកានោះចូលជាស្ថាពរ[16]។ អង្គបុរេជំនុំជម្រះបានអះអាងបញ្ជាក់ពីចំណុចនេះ[17] ហើយសហចៅក្រមស៊ើបអង្កេតក៏បានរំឭកផងដែរនៅក្នុងពេលចេញដីកាសម្រេច។ អ្នកទាំងនោះបានអះអាងបន្ថែមពី "សមត្ថកិច្ច*យុត្តាធិការរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មទាំងនេះ*" ក៏បានពណ៌នាពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌផ្សេងៗ និងពីការកំណត់ពីចរិតលក្ខណៈផ្លូវច្បាប់អនុវត្ត ព្រមទាំងសមត្ថភាពរបស់ខ្លួនក្នុងការ "*បកស្រាយបទបញ្ញត្តិដែលទាក់ទងទៅនឹងសមត្ថកិច្ចរបស់ខ្លួន*"[18] ។ ដូច្នេះ បណ្តឹងឧទ្ធរណ៍មានលក្ខណៈអាចទទួលយកបាន ដោយផ្អែកទៅលើមូលដ្ឋានគ្រឹះនៃវិធាន ៦៧ (៥) និង៧៤ (៣) (ក) នៃវិធានផ្ទៃក្នុង។

១៥. ដូចសេចក្តីគូសបញ្ជាក់របស់លោក ខៀវ សំផន នៅក្នុងបណ្តឹងឧទ្ធរណ៍ និងការទទួលស្គាល់ពីសហព្រះរាជអាជ្ញាដូច្នោះដែរ អង្គបុរេជំនុំជម្រះចាត់ទុកថា "*វិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវឱ្យអង្គបុរេជំនុំជម្រះអនុម័តយកការបកស្រាយទូលំទូលាយ ទៅលើសិទ្ធិនៃជនត្រូវចោទក្នុងការដាក់បណ្តឹងឧទ្ធរណ៍ ដើម្បីធ្វើយ៉ាងណាអាចធានាបាននូវសិទ្ធិរបស់ជននោះ ក្នុងការទទួលបាននូវការកាត់សេចក្តីប្រកបដោយយុត្តិធម៌*"[19] (កថាខណ្ឌ ១៨)។ ក៏ប៉ុន្តែ ដីកាដំណោះស្រាយបែរជារំលោភទៅលើវិធាននៃការស៊ើបអង្កេត រំលោភទៅលើសិទ្ធិទទួលបាននូវការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ហើយលោក ខៀវ សំផន មានសេចក្តីទុកចិត្តទៅលើអំណាចឆន្ទានុសិទ្ធិស្វយ័តនៃអង្គបុរេជំនុំជម្រះ ដើម្បីសុំឱ្យប្រកាសថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយផ្អែកទៅលើមូលដ្ឋានគ្រឹះនៃវិធាន ២១ (១)[20]។

---

[15] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដូចខាងលើ កថាខណ្ឌទី៥០-៥១

[16] វិធាន៧៩ នៃវិធានផ្ទៃក្នុង

[17] ដីកាសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទាក់ទិនទៅនឹងបណ្តឹងប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D345/5/11* កថាខណ្ឌ ១១

[18] ដីកាដំណោះស្រាយ ចុះថ្ងៃទី15 ខែកញ្ញា ឆ្នាំ២០១០ ដូចខាងលើ កថាខណ្ឌ១៣០១ ១៣០២ និង១៣០៨

[19] ដីកាសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឱ្យលោកដាក់ចម្លើយ និងសេចក្តីសង្កេតបន្ថែមទៅលើដីកាសន្និដ្ឋានស្ថាពរ (...) ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D390/1/2/4* កថាខណ្ឌ១៣

[20] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដូចខាងលើ កថាខណ្ឌ ៥៣ និង៥៤

១៦. នៅក្នុងលក្ខខណ្ឌទាំងនេះ អ្នកដាក់ពាក្យបណ្ដឹងត្រូវទទួលបានបណ្ដឹងដ៏ពិតប្រាកដ ដើម្បីអាចតវ៉ាចំពោះដីកាសម្រេច ដោយសារតែការស៊ើបសួរមិនមានលក្ខណៈមិនពេញលេញ និងលំអៀង[21]។ នៅក្នុងរឿងក្ដី *Walchli តទល់នឹងប្រទេសបារាំង* តុលាការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប បានចាត់ទុកថា ការដែលមិនអាចតវ៉ាទៅនឹងនិយ័តភាពនៃនីតិវិធីស៊ើបសួរ គឺប្រៀបបីដូចជាការលុបបំបាត់សិទ្ធិទទួលបានការកាត់ក្ដីពីថៅក្រម ក៏ដូចជាការរំលោភលើសិទ្ធិទទួលបាននូវការកាត់សេចក្ដីប្រកបដោយយុត្តិធម៌ ដូចដែលមានចែងនៅក្នុងមាត្រា ៦ កថាខណ្ឌ១ ៖ "*ដោយបានឃើញផលវិបាកដែលបណ្ដាលមកពីការមិនទទួលយកបណ្ដឹងនៃអ្នកដើមបណ្ដឹង ដែលគាត់មិនអាចតវ៉ាទៅលើនីតិវិធី ដែលគាត់នោះយល់ថា អាចជំទាស់បាននៅចំពោះមុខ យុត្តាធិការស៊ើបអង្កេត និងយុត្តាធិការជំនុំជម្រះ (...) តុលាការវាយតម្លៃថា អ្នកដើមបណ្ដឹង ត្រូវបានគេបង្ខំឱ្យទទួលយកបន្ទុកមួយមិនសមស្រប ដែលនាំឱ្យបាត់លំនឹងរវាងសេចក្ដីប្រាថ្នាស្របច្បាប់ក្នុងការធានាឱ្យបាននូវការគោរពលក្ខខណ្ឌផ្លូវការ ដើម្បីប្ដឹងទៅតុលាការ និងសិទ្ធិទទួលបានការកាត់ក្ដីពីថៅក្រម (...)*"[22]។

ក. ការអនុវត្តខុសឆ្គងចំពោះវិធាននៃការស៊ើបសួរ

១៧. ទី១ ឯកសារយោងដ៏ច្រើនរបស់សហព្រះរាជអាជ្ញាទៅលើការអនុវត្តនៅតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសយូហ្គូស្លាវី មិនអាចយកមកអនុវត្តបានឡើយ ព្រោះថា តុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសយូហ្គូស្លាវី គឺជាតុលាការដែលទទួលឥទ្ធិពលខ្លាំងពីប្រពៃណីច្បាប់ common law ដែលនៅតុលាការនេះ <u>មិនមានដំណាក់កាលស៊ើបសួរទេ</u>។ ដូច្នេះ យើងមានការងឿងឆ្ងល់ជាខ្លាំងពីការប្រើប្រាស់បទបញ្ញត្តិច្បាប់ដែលឃ្លាតឆ្ងាយ ពីប្រពៃណីច្បាប់ដែលមានជាធរមាននៅទីក្រុងភ្នំពេញនេះណាស់។ ហេតុដូចនេះ ដោយបង្ខំឱ្យអង្គបុរេជំនុំជម្រះមិនសម្រេចសេចក្ដី សហព្រះរាជអាជ្ញាបានបន្ថំយុត្តិសាស្ត្រនៅតុលាការនេះ ដើម្បីលើកឡើងពីអំណាចដែលមានកម្រិតព្រំដែន ក្នុងបណ្ដឹងឧទ្ធរណ៍របស់សាលាដំបូង នៅតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសយូហ្គូស្លាវី (កថាខណ្ឌ ៦)។

---

[21] សារណាបណ្ដឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដូចខាងលើ កថាខណ្ឌទី៨៥ ដល់ទី១០៩

[22] ករណី តុលាការសិទ្ធិមនុស្សអឺរ៉ុប Walchli តទល់នឹងប្រទេសបារាំង ថ្ងៃទី២៦ កក្កដា ២០០៧ បណ្ដឹងលេខ 35787/03 កថាខណ្ឌ ៣៦ និង៣៧ (ឧបសម្ព័ន្ធ)

១៨. ជាងនេះទៀត សហព្រះរាជអាជ្ញាយោងតែទៅលើវិធាន ៧២ (ឃ) នៃវិធាននីតិវិធី និងភស្តុតាងនៅតុលាការព្រហ្មទណ្ឌសម្រាប់ប្រទេសយូហ្គូស្លាវី ដើម្បីកំណត់សញ្ញាណនៃយុត្តាធិការ តាមន័យចង្អៀតបំផុត (កថាខណ្ឌ ៧)។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា "*វិធានផ្ទៃក្នុងមិនបានកំណត់និយមន័យនៃយុត្តាធិការឡើយ* (កថាខណ្ឌ ៧)។ ដោយសារតែគ្មានការកំណត់និយមន័យ នៅក្នុងវិធាននានាក្នុង អ.វ.ត.ក និងក្នុងច្បាប់កម្ពុជា - ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានត្រឹមតែរៀបរាប់ពីដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេត ដែលអាចបើកផ្លូវប្តឹងឧទ្ធរណ៍បាន[23] - គេគប្បីផ្តល់សេចក្តីទុកចិត្តទៅលើអំណាចឆន្ទានុសិទ្ធិនៃអង្គជំនុំជម្រះ ដែលនឹងចេញជាយុត្តិសាស្ត្រដោយខ្លួនឯង ជាជាងធ្វើតាមប្រព័ន្ធច្បាប់ common law ដែលមកពីទីផ្សេង និងចាកប្រធានសុទ្ធសាធ។

១៩. ក្នុងន័យនេះ នៅក្នុងបណ្តឹងឧទ្ធរណ៍ លោក ខៀវ សំផន បានសុំឱ្យអង្គបុរេជំនុំជម្រះ យកគំនិតតាមមាត្រា ១៨៦ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលស្រដៀងគ្នាខ្លាំងបំផុតទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់ Civil law[24]។ ដោយហេតុថា ចាប់តាំងពីមានច្បាប់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២000 ដែលពង្រឹងការការពារគោលការណ៍សន្មតជាមុនថាគ្មានទោស និងសិទ្ធិនៃជនរងគ្រោះខាងព្រហ្មទណ្ឌនោះមក ជនជាប់ចោទមានលទ្ធភាពធ្វើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះរបស់ចៅក្រមស៊ើបអង្កេត។ តាមបញ្ញត្តិនៃសារាចរណែនាំទាក់ទិននឹងការវិវត្តនីតិសាស្ត្រនេះ "*លទ្ធភាពក្នុងការដាក់បណ្តឹងឧទ្ធរណ៍បែបនេះ ត្រូវបានវិនិច្ឆ័យថាពិតជាចាំបាច់ អាស្រ័យដោយសារសារសំខាន់នៃបញ្ហាប្រឈម ដែលពាក់ព័ន្ធទៅនឹងការកំណត់ចរិតលក្ខណៈនៃអំពើឧក្រិដ្ឋ ដើម្បីអាចឱ្យ<u>អង្គជំនុំជម្រះអាចត្រួតពិនិត្យលើការស៊ើបសួរ</u> ស្តីពីលក្ខណៈគ្រប់គ្រាន់នៃការដាក់បន្ទុកប្រឆាំងនឹងជនជាប់ចោទ <u>ទាំងលើអង្គហេតុ</u> (ការត្រួតពិនិត្យនេះស្តែងចេញនូវអធិបតេយ្យភាពនៃអង្គជំនុំជម្រះ) ក៏ដូចជា<u>លើអង្គច្បាប់</u> គឺការវាយតម្លៃទៅលើភាពសមស្របនៃការកំណត់ពីចរិតលក្ខណៈផ្លូវច្បាប់ ដែលគេអាចដាក់ឱ្យអង្គជំនុំជម្រះឧក្រិដ្ឋកម្មនៃសាលាវិនិច្ឆ័យត្រួតពិនិត្យ ក្នុងករណីបណ្តឹងសារទុក្ខ*"។[25]

---

[23] មាត្រា ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[24] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដូចខាងលើ កថាខណ្ឌ ៥២

[25] សារាចរលេខ CRIM 00-14 F1 ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២000 ស្តីបញ្ញត្តិច្បាប់ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២000 ដើម្បីពង្រឹងការការពារសច្ចធារណ៍និរទោស និង សិទ្ធិនៃជនរងគ្រោះពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌ ១.៣.១ (ក្នុងឧបសម្ព័ន្ធ)

២០. ទីពីរ ប្រសិនជាវិធាន ៨៧ នៃវិធានផ្ទៃក្នុង និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានចែងថា សាលាដំបូងចេញសេចក្តីសម្រេច ដោយផ្អែកលើភស្តុតាងដែលបានពិភាក្សាដេញដោលនៅសវនាការ (កថាខណ្ឌ ៩) នោះភស្តុតាងសម្រាប់គាំទ្រដីកាដំណោះស្រាយមានសារសំខាន់ណាស់ ព្រោះថា *"សាលាដំបូងទទួលបានដីកាបញ្ជូនរឿងទៅជម្រះ ពីសហចៅក្រមស៊ើបអង្កេត ឬសាលដីកាពីអង្គបុរេជំនុំជម្រះ"*[26] ហើយសាលាដំបូង *"សម្រេចត្រឹមតែលើអង្គហេតុណាដែលមានបង្ហាញ នៅក្នុងដីកាបញ្ជូនរឿងទៅជម្រះតែប៉ុណ្ណោះ"*[27]។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញា មិនស្គាល់ប្រព័ន្ធពិសេសនៃច្បាប់ *civil law* និងតួនាទីដ៏សំខាន់នៃដំណាក់កាលស៊ើបសួរសោះឡើយ។

២១. ទីបី ដីកាដំណោះស្រាយ ដែលជាខណៈចុងក្រោយនៃការស៊ើបសួរ គឺជាឱកាសចុងក្រោយសម្រាប់ក្រុមមេធាវីការពារក្តីលើកឡើងពីអំណះអំណាងរបស់ខ្លួន។ នៅពេលដែលដីកាដំណោះស្រាយនោះចូលជាស្ថាពរហើយ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ នឹងអាចត្រូវបានលើកឡើងទៀតបានឡើយ[28]។ ដូច្នេះ ផ្ទុយពីយោបល់សហព្រះរាជអាជ្ញា (កថាខណ្ឌ ២០ ដល់ ២៣) ដែលថា ជនជាប់ចោទត្រូវមានសិទ្ធិលើកឡើងពីបញ្ហាដែលចោទសួរនៅពេលស៊ើបអង្កេត រីឯ "បណ្តឹងឧទ្ធរណ៍" មិនអាច*"ជាការប៉ុនប៉ងរបស់លោក ខៀវ សំផន ក្នុងការប្តឹងពីបញ្ហានានាដែលគាត់ខកខានមិនបានជំទាស់ឲ្យទាន់ពេលវេលា ក្នុងយន្តការនីតិវិធីដ៏ត្រឹមត្រូវមួយ"* (កថាខណ្ឌ ១៧)។ ប្រសិនបើការរំលោភបំពានខ្លះដែលបានលើកឡើងក្នុង"បណ្តឹងឧទ្ធរណ៍"គឺជាកម្មវត្ថុនៃការតវ៉ាជាមុននិងក្នុងសេចក្តីសម្រេចផ្សេងគ្នាក្តី ភាពមិនប្រក្រតីដែលចេះតែមានបន្តបន្ទាប់ឥតឈប់នេះបង្កឲ្យមានឧប្បត្តិហេតុធ្ងន់ធ្ងរទៅលើសមភាពនៃការកាត់ក្តី ហើយមិនអាចបញ្ជូនរឿងលោក ខៀវ សំផន ទៅជម្រះនៅសាលាដំបូងបានឡើយ។ ចំណុចទាំងនេះ សុទ្ធតែត្រូវបានទទួលស្គាល់ដោយអ្នកជំនាញបានអញ្ជើញមកវាយតម្លៃគុណភាពនៃការស៊ើបសួរ រួមមានសាស្ត្រាចារ្យ Bernard BRANCHET (ក្រុង Metz) Mathieu GUIDERE (ក្រុង Genève) ក៏ដូចជាអ្នកស្រី Elena GRASSO (Turin) និង Sylvie MONTJEAN-DECAUDIN (Paris Ouest)[29]។

---

[26] វិធាន៧៩(១) នៃវិធានផ្ទៃក្នុង

[27] វិធាន៩៨(២) នៃវិធានផ្ទៃក្នុង

[28] វិធាន៧៦(៧) នៃវិធានផ្ទៃក្នុង

[29] BRANCHET (B), ការវិភាគទិតៀនការស៊ើបអង្កេតដំបូង និងវិភាគទាក់ទងដល់ការគោរពការកាត់សេចក្តីប្រកបដោយ

<u>៤. ការមិនគោរពដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ</u>

២២. ផ្ទុយពីការលើកឡើងរបស់សហព្រះរាជអាជ្ញា (កថាខណ្ឌ ១០) អង្គបុរេជំនុំជម្រះបានទទួលស្គាល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានឯកសារបកប្រែជាភាសាបារាំង នៃដីកាដំណោះស្រាយ ភស្តុតាងចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ការកំណត់យោងចុងទំព័ររាល់សេចក្តីសម្រេច និងដីកាសម្រេចរបស់ចៅក្រម និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគីទាំងឡាយ[30]។ លើសពីនោះ អង្គបុរេជំនុំជម្រះបានបង្គាប់ឱ្យមានការបកប្រែជាភាសាបារាំងនូវរាល់កំណត់យោងចុងទំព័រ នៃដីកាដំណោះស្រាយ[31] ដែលកំណត់នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០[32]។ដោយសូមឱ្យអង្គបុរេជំនុំជម្រះអនុវត្តសេចក្តីសម្រេចរបស់ខ្លួនទៅលើការបកប្រែទាំងស្រុង[33] លោក ខៀវ សំផន បានសុំឱ្យអង្គបុរេជំនុំជម្រះ ធានានូវការបកប្រែជាភាសាបារាំងដោយឥតបង្អង់នូវឯកសារទាំងអស់ ដែលយោងនៅក្នុងដីកាដំណោះស្រាយ ព្រោះថាបើគ្រាន់តែបកប្រែលេខយោងចុងទំព័រនៃឯកសារ គឺមិនអាចទទួលយកបានឡើយវាអាចជះឥទ្ធិពលដល់ការវិនិច្ឆ័យក្តីនាពេលខាងមុខ ដែលមិនស្វែងរកខ្លឹមសារនៃឯកសារដែលលើកយកនិយាយនោះ។

---

យុត្តិធម៌ ឯកសារតុលាការលេខ D427/4/3.1.22 ។ GRASSO (E), ការទិតៀនការបកប្រែចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ សំណុំរឿងលេខ 002/21-10-2010- អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ១៥) ឯកសារតុលាការលេខ 1.1.18 ។ GUIDERE (M) បញ្ហានៃការបកប្រែនិងហានិភ័យនៃការបាត់បង់ព័ត៌មាន សំណុំរឿងលេខ 002/21-10-2010- អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ១៥) ឯកសារតុលាការលេខ 1.1.19 ។ MONJEAU-DECAUDIN (S) បញ្ហានៃការបកប្រែនៅក្នុងសំណុំរឿងរបស់លោកខៀវ សំផន និងផលវិបាកទៅលើការសម្រេចសេចក្តី ដូចគ្នា ឯកសារតុលាការលេខ 1.1.19 ។

[30] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផន ប្រឆាំងទៅនឹងដីកាសម្រេចស្តីពីការកំណត់លើសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីទាក់ទងការបកប្រែ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារតុលាការលេខ *A190/I/20*

[31] សេចក្តីបង្គាប់ដល់អង្គភាពបកប្រែទាក់ទិននឹងការបកប្រែលេខយោងជើងទំព័រជាភាសាបារាំងនៃដីកាដំណោះស្រាយ និងការអនុញ្ញាតដល់មេធាវីការពារក្តីរបស់ លោក ខៀវ សំផន ក្នុងការដាក់អំណះអំណាងបន្ថែម ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ *ERN 00619919* (ភាសាបារាំង)

[32] អ៊ីម៉ែលជូនដំណឹង ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ទាក់ទិនទៅនឹងការដាក់ចូលក្នុងសំណុំរឿងនូវដីកាដំណោះស្រាយដែលកែរួច ឯកសារតុលាការលេខ D427។

[33] ដីកាសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផនប្រឆាំងទៅនឹងដីកាសម្រេចដែលកំណត់សិទ្ធិ និងកាតព្វកិច្ចនៃភាគីក្នុងការបកប្រែ ដូចខាងលើ

២៣. រីឯសិទ្ធិឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរវិញ សហព្រះរាជអាជ្ញាបានអះអាងមិនត្រឹមត្រូវដែលថា *"ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានសុំបំពេញសិទ្ធិនេះទេ ឲ្យបានទាន់ពេលឡើយ"* (កថាខណ្ឌ ១៥) ព្រោះ លោក ខៀវ សំផន ទើបតែទទួលបានដីកាសន្និដ្ឋានស្ថាពរជាភាសាបារាំង នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ នេះប៉ុណ្ណោះ[34] ពោលគឺបន្ទាប់ពីការឆ្លើយតបរបស់សហព្រះរាជអាជ្ញា - ដែលនេះជាការរំលោភលើសិទ្ធិទទួលបានការបកប្រែរបស់គាត់។

២៤. ដោយយកលេសថា ជម្រុញអង្គជំនុំជម្រះមិនឱ្យសម្រេចសេចក្តីឱ្យស៊ីជម្រៅ សហព្រះរាជ-អាជ្ញាបានអះអាងថា អង្គបុរេជំនុំជម្រះមិនអាចជំនួសអំណាចឆន្ទានុសិទ្ធិរបស់សហចៅ-ក្រមស៊ើបអង្កេតឡើយ ក្នុងក្របខណ្ឌនៃបណ្តឹងឧទ្ធរណ៍នេះ (កថាខណ្ឌ ១៦)។ តែទោះជាយ៉ាងណា ដូចការរំឭកប្រាប់ របស់លោក ខៀវ សំផន ដូច្នោះដែរ អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចពិនិត្យទៅលើភាពមិនប្រក្រតីនៃនីតិវិធី និងមានអំណាចកែប្រែការវាយតម្លៃចរិតលក្ខណៈជាគតិយុត្តិរបស់សហចៅក្រមស៊ើបអង្កេត[35]។ សាលដីកានៃអង្គបុរេជំនុំជម្រះ នឹងបដិសេធដីកាបញ្ជូនរឿងទៅជម្រះ។ សហចៅក្រមស៊ើបអង្កេតបានបញ្ចូលតែភស្តុតាងដាក់បន្ទុក ហើយច្រានចោលភស្តុតាងដោះបន្ទុក។ ដីកាដំណោះស្រាយបង្ហាញនូវភាពបាត់លំនឹងយ៉ាងជាក់ស្តែង និងយ៉ាងអាម៉ាស់ ដែលបណ្តាលមកពីភាពលំអៀងនៃចៅក្រម Marcel LEMONDE។ ការងារដ៏ខ្ជីខ្ជារបស់គាត់ទៅលើជនជាប់ចោទនេះ ត្រូវបានជំទាស់ដោយគ្រប់ភាគីក្នុងរឿងក្តី និងនៅក្នុងជំនួបអន្តរជាតិនានា[36]។ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចក្នុងការប្រកាសពីអំណះអំណាងសំខាន់ៗរបស់លោក ខៀវ សំផន ដែលរួមស្វែងរកការពិត។

**អាស្រ័យហេតុនេះ**

២៥. លោក ខៀវ សំផន សុំឱ្យអង្គបុរេជំនុំជម្រះ ៖

- ច្រានចោលអំណះអំណាងរបសស់សហព្រះរាជអាជ្ញា
- ប្រកាសថាបណ្តឹងឧទ្ធរណ៍របស់ លោក ខៀវ សំផនអាចទទួលយកបាន និងមានមូលដ្ឋានត្រឹមត្រូវ។

---

[34] អ៊ីម៉ែលជូនដំណឹង ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ទាក់ទិនទៅនឹងការដាក់ចូលក្នុងសំណុំរឿងនូវដីកាសន្និដ្ឋានស្ថាពរនៃសហព្រះរាជអាជ្ញា (វិធាន៦៦) ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ឯកសារតុលាការលេខ *D390*

[35] សារណាបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាដំណោះស្រាយ ដូចខាងលើ កថាខណ្ឌ៥៥ ដល់៥៧

[36] VERGÈS (J), "តុលាការអន្តរជាតិ?" Gazette du Palais, តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអឺរ៉ុប លេខ៣៣០-៣៣១ ថ្ងៃទី២៦-ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១០

២៦. ដូច្នេះ ៖

- លុបចោលដីកាដំណោះស្រាយ
- បង្គាប់ឱ្យដោះលែង លោក ខៀវ សំផន ឱ្យមានសេរីភាពឡើងវិញ
- បង្គាប់ឱ្យបន្តការស៊ើបសួរ។

២៧. ទោះបីជាយ៉ាងណាក៏ដោយ

- វិនិច្ឆ័យថា មិនអាចបញ្ជូនសំណុំរឿង លោក ខៀវ សំផន ទៅជម្រះ ដោយស្ថានភាពមិនគ្រប់ជ្រុងជ្រោយបែបនេះ បានឡើយ។

**រក្សាសិទ្ធិកែប្រែគ្រប់បែបយ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី **សា សូវាន**<br>មេធាវី **Philippe GRECIANO**<br>មេធាវី **Jacques VERGÈS** | ភ្នំពេញ<br>ប៉ារីស | [signatures] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |